# ការសំភាសន៍របស់ សំ សារឿន

កៈ អ្នកដែរសំភាសន៍ ជាង ស៊ីអ៊ារ ខៈ អ្នកដែរអោយគេសំភាសន៍ សំ សារឿន

កៈ ចឹងជាដំបូងខ្ញុំអរគុណច្រើពូដែរបានអោយខ្ញុំបានសំភាសន៍ពីប្រវត្តិរបស់ពូ ហើយការសំភាសន៍នេះត្រូវបានរៀបចំឡើងដោយសកលវិទ្យាល័យមួយដែរនៅអាមេរិចហាស ដែរមានឈ្មោះថាBYU ហើយដោយសារតែសកលវិទ្យាល័យមានគោលបំណងទុកអោយកូនចៅជំនាន់ក្រោយៗពួកគាត់បានស្គាល់ពីប្រវត្តិប្រជាជនខ្មែរ នឹងដើម្បីអោយពួកគាត់អាចបានស្គាល់ពីប្រវត្តិឪពុកម្ដាយ នឹងជីដូនជីតាចឹងហាសពូ សំរាប់ការសំភាសន៍មួយនេះនៅពេលដែរខ្ញុំសំភាសន៍ចប់ខ្ញុំនឹងដាក់ការសំភាសន៍មួយនឹងទៅក្នុងវេបសាយរបស់សាលា ដែរមានឈ្មោះថា www.cambodianoralhistories.byu.edu ចឹងហាសពូ បាទចឹងសំរាប់ពូតើពូយល់ព្រមដើម្បីអោយខ្ញុំដាក់ការសំភាសន៍មួយនេះទៅក្នុងវេបសាយរបស់សាលាដែរទេពូ?

ខៈ មានអីទេលោកគ្រូ

កៈ ចឹងដោយសារតែខ្ញុំចង់នៅជិតពូបន្តិចដោយសារតែត្រូវrecordសំលេងចឹងហាសខ្លាចវាអត់លឺចឹងហាសពូ?

ខៈ បាទអត់អីទេ

កៈ ចឹងសំរាប់ខ្ញុំជាអ្នកសំភាសន៍ពូខ្ញុំមានឈ្មោះថា ជាង ស៊ីអ៊ារ ហើយថ្ងៃខែដែរខ្ញុំសំភាសន៍ពូគឺនីថ្ងៃទី23 ខែ1 ឆ្នាំ2018 ហើយខ្ញុំសំភាសន៍ពូនៅភូមិ4 សង្កាត់ផ្សារដើមថ្កូវ ខ័ណ្ឌចំការមន នៅរាជធានីភ្នំពេញហាសពូ?

ខៈ បាទលោកគ្រូ

កៈ បាទចឹងសំរាប់ពូឈ្មោះពេញរបស់ពូមានឈ្មោះអីគេដែរពូ?

ខៈ បាទខ្ញុំមានឈ្មោះថា សំ សារឿន លោកគ្រូ

កៈ បាទឈ្មោះ សំ សារឿន ណាពូ ចុះមានឈ្មោះហៅក្រៅទេពូ?

ខៈ ទេអត់មានទេ

កៈ អត់មានទេណាពូ ចុះកាលពីក្មេងមាននរណាហៅឈ្មោះពូអីផ្សេងពីនឹងអត់ពូ?

ខៈ មានតាលោកគ្រូគេហៅអានេះអានោះគេហៅលេងសើចអីចឹងហាស

កៈ បាទគេហៅលេងសើចប៉ុន្តែគេហៅឈ្មោះអីទៅពូ?

ខៈ គេហៅថាឈ្មោះឪអារុញ ឪអាម៉ៅ

កៈ បាទឪអារុញ

ខៈ ហៅឪអាខ្វិលអីចឹងហាស

កៈ ចុះពូអាយុប៉ុន្មានដែរឆ្នាំនឹងពូ?

ខៈ ខ្ញុំអាយុ48ឆ្នាំហើយ

កៈ ពូអាយុ48ឆ្នាំ ចុះសំរាប់ថ្ងៃខែ ឆ្នាំកំណើតពូ តើពូមានដឹងថាពូកើតនៅថ្ងៃ ខែ ឆ្នាំណាដែរទេពូ?

ខៈ ថ្ងៃបើដាក់ក្នុងអត្តសញ្ញាណប័ណ ថ្ងៃខែឆ្នាំកំណើត ថ្ងៃទី2 ខែ5 ឆ្នាំ1970គត់

កៈ ឆ្នាំ1970គត់បាទត្រូវហើយ

ខៈ នឹងហើយឆ្នាំ70

កៈ ចឹងសំរាប់ឆ្នាំច័ន្ទគតិពូឆ្នាំអីគេ ដូចជាឆ្នាំជូត ឆ្លូវ ខាល ថោះអីហាសពូ?

ខៈ ឆ្នាំជូត

កៈ ឆ្នាំជូតមែនទេពូ?

ខៈ បាទឆ្នាំជូត

កៈ ចុះទីកន្លែងដែរពូកើតតើពូកើតនៅភូមិអី ឃុំអី ស្រុកអី ខេត្តអីចឹងហាសពូ?

ខៈ បាទខ្ញុំកើតនៅភូមិចំបក ឃុំគ្រួស

កៈ នៅស្រុកស្វាយជ្រុំ ខេត្តស្វាយរៀង?

ខៈ ស្រុកស្វាយជ្រុំ ខេត្តស្វាយរៀង កាលពីមុនគេដាក់ស្រុកស្វាយរៀង ខេត្តស្វាយរៀងភូមិរបស់ខ្ញុំនឹងនៅខាងក្រៅបញ្ជីគេហៅថាភូមិព្រៃតាសុខ តែគេដាក់ក្នុងបញ្ជីជាតិគេដាក់ភូមិឈើទាល់ ក៏ខ្លះគេថាអូនៅឃុំគ្រួស គេថាអូទៅភូមិស្វាយធំវានៅតែម្នាក់អែងហាសលោកគ្រូ ចឹងគេបានដាក់ចូលនៅក្នុងបញ្ជីជាតិដាក់ភូមិគ្រួសតែម្តងទៅ ចឹងចូលភូមិគ្រួសតែម្តង

កៈ ខ្ញុំបានសំភាសន៍អ្នកមីងនោះគាត់បានថាភូមិគ្រួស ឃុំថ្នាល់?

ខៈ ឃុំថ្នាល់?

កៈ អានឹងនៅជាប់គ្នាតាហីពូ?

ខៈ ឆ្ងាយពីគ្នា

កៈ ប៉ុន្តែនៅក្នុងភូមិតែមួយទេ?

ខៈ ភូមិនៅជាមួយគ្នានឹង

កៈ ប៉ុន្តែតែមួយនៅស្រុកស្វាយជ្រុំ ខេត្តស្វាយរៀងតែមួយទេ?

ខៈ ដូចតែគ្នាដូចយើងចឹងហាសជាប់គ្នាតែមួយនឹងចាប់គ្នាហាស

កៈ ចុះពូមានបងប្អូនប៉ុន្មាននាក់ដែរពូ?

ខៈ បាទខ្ញុំមានបងប្អូន10នាក់លោកគ្រូ

កៈ បងប្អូនរបស់ពូ?

ខៈ បាទលោកគ្រូបងប្អូន

កៈ អូច្រើនហាសពូ ចុះពូជាកូនទីប៉ុន្មានដែរទៅពូ?

ខៈ ខ្ញុំជាកូនទី6

កៈ ពូជាកូនទី6ចុះមានស្រីប៉ុន្មាន ហើយមានប្រុសប៉ុន្មានពូមានចងចាំទេ?

ខៈ មានប្រុស6នាក់ ស្រីមាន4នាក់

កះ អូបាទ ចុះពូមានចងចាំបងប្អូនរបស់ពូមានឈ្មោះអីគេខ្លះអត់ពូ?

ខះ បងទី1 មានឈ្មោះ សំអឿន ស្រី

កះ ចុះទី2វិញ?

ខះ ទី2មានឈ្មោះសំ សារឿន ស្លាប់ដោយសារតែលង់ទឹកអាយុ18ឆ្នាំ

កះ ប៉ុន្តែស្លាប់បាត់ហើយ?

ខះ បាទៗហើយ

កះ ចុះទី3វិញ?

ខះ ទី3ឈ្មោះ សំ សារិន ស្រីដែរ3នាក់នឹងស្រីទាំងអស់នឹង ទី4 ឈ្មោះ សំ ប៊ុន ធឿន បានស្លាប់បាត់ហើយអាយុ52ឆ្នាំ

កះ ចុះទី5វិញ?

ខះ ទី5ឈ្មោះ សំប៊ុន ថន

ក. ចុះទី6វិញបង?

ខះ ទី6ខ្ញុំនឹងអែង

កះ ចុះទី7វិញបង?

ខ. ទី7 ឈ្មោះ សំ សារី ស្រី

ក. ចុះទី8វិញ?

ខះ ទី8 ឈ្មោះ សំ វៃម ប្រុស ទី9 ៣គេ សំរាប

កះ ខ្ញុំមានអារម្មណ៍ថា ដូចជាខ្ញុំធ្លាប់សំភាសន៍ទាក់ទងជាមួយមួយនឹង ចុះពូមានបងប្អូនណាដែររស់នៅម្តុំនឹងទេ?

ខះ អត់មានទេ

កះ ពីមុនខ្ញុំធ្លាប់សំភាសន៍ដូចជាមានបងប្អូនចំនួន10នាក់ហើយមានឈ្មោះមួយនឹង ដូចអីដែរពូបានរៀបរាបមិញនឹងដូចជាត្រូវនឹងអីដែរមានចឹងហាស?

ខ  បើមាន មានតែខ្សែហានឹង

ក៖ អូមានតែខ្សែហាហោសពូ?

ខ៖ បើមានខ្សែហាមានដូចជាកូនក្មួយអីមាន

ក៖ អូបាទប្រហែលជាចឹងហើយមើលទៅ?
ខ៖ នឹងត្រកូលសោមដែរនឹង

ក៖ ខ្ញុំចាំថាដូចជាមានឈ្មោះ សំ សារី

ខ៖ នឹងម៉ែឪរបស់ខ្ញុំនឹង

ក៖ មានដូចជា សំ សារឿនស្អីនឹង ខ្ញុំបានភ្លេចឈ្មោះហើយប៉ុន្តែគ្រាន់តែស្រដៀងចឹងហាស
ចឹងពូមានចងចាំសាច់រឿងអីជាមួយពួកគាត់កាលពូនៅក្មេងៗអត់ពូ
ធ្លាប់បានធ្វើអីជាមួយគ្នាអីចឹងហាសពូ?

ខ៖ ជាមួយពុកម្ដាយហោស?

ក៖ បាទពូ

ខ. ជាមួយពុកម្ដាយពួកគាត់ស្លូតៗណាស់លោកគ្រូអើយ
គាត់ក្រមែនគាត់មិនដែរបានធ្វើបាបកូនចៅទេ
តែកូនអោយទៅនៅខ្ញុំគេក៏មិនអោយទៅនៅដែរនឹង
គាត់ថាបើឪចិញ្ចឹមមិនរស់ក៏មិនអោយកូនទៅដែរ សុខចិត្តបើស្លាប់ក៏ស្លាប់ទាំងឪនឹងកូនដែរ
មិនអោយគេធ្វើបាបទេ

ក៖ អូចឹងហោសពូចុះ?

ខ៖ ហើយកាលដែរខ្ញុំរត់ក៏ចឹងដែរលោកគ្រូ ខ្ញុំរត់សម័យសង្គ្រាមនឹងខ្ញុំរត់បែបម៉ែ
បែកឪនឹងកូនរកម៉ែរកឪកាលណុងម៉ែឪគែរកសំលាប់ចោលនោះ
ថាឪអើយឪៗអែងមិនទៅចាំយកកូនផងឪ នោះគេអត់មានម៉ែមានឪទេកូន
យើងត្រូវគិតពីខ្លួនយើងសិនកូន មិនដឹងជារបៀបម៉េចទេយើង បើចឹងឪអែងអៀវខ្ញុំទៅ
កូនអើយកុំអោយឪអៀវអី ឪដើរលែងរួចហើយ

ក៖ ចុះពូកាលពីនៅក្មេងតើពូចូលចិត្តលេងអីជាមួយបងប្អូនរបស់ពូដែរហោពូ?

ខ. ចូលចិត្តលេងក្រឡាខ្វងលោកគ្រូ

ក៖ លេងក្រឡាខ្វងណាពូ ចុះលេងបិទពួន គប់កំប៉ុង គប់ឈូសអីវិញពូ?

ខ៖ លេងបិទពួន លេងលោតអន្ទាក់

ក៖ លេងផ្ទាត់កៅស៊ូកងអីលេងទេ?

ខ៖ លេងផ្ទាត់កៅស៊ូកង លេងគប់ថុយ លេងអីចឹងទៅ

ក៖ បាទលេងថុយ លេងអាមឹកដែរហោសពូ លេងលោតមឹកលេងអី ពូមានធ្លាប់លេងទេ?

ខ៖ មឹកអត់ស្គាល់ទេមឹក

ក៖ ចុះពូលេងអីទៀត?

ខ. លេងលោតកំពស់ លេងទាញព្រាតលេងអី

ក៖ ចុះពូធ្លាប់មានអនុស្សាវរីយ៍ទៅស្រែអីជាមួយបងប្អូនទេ?

ខ៖ ទៅស្រែអីនឹងបានត្រឹមប្រលែងគ្នា
ច្រូតស្រូវប្រលែងគ្នាៗជូនកាលលែងតែប្រលែងគ្នាចឹងទៅ
លេងទឹកលេងអីណែទឹកត្រឹមជង្គង់ ហើយនឹងហែលទឹកហែលអី
ជូនកាលលែងតែលេងចឹងទៅមិនបានច្រូតម៉ែដេញវៃ

ក៖ អូចឹងហោសពូ?

ខ៖
បាទហើយនៅតូចចឹងទៅរៀនម៉ែដាំបាយចឹងទៅម៉ែអោយដាំបាយអូនហែងដាំបាយទៅកូន
ហាស ខ្ញុំថាខ្ញុំមិនដាំទេចុះបើមិនដាំយ៉ាងម៉េចម៉ែជាប់ប្អូន
ហើយបានដាំបាយពេលដាំបាយផងយំផងអាបង
ហើយអញ់មិនប្រើទេម៉ែប្រើតែហែងវាអង្គុយសើចដល់ពេលដែរខ្ញុំខឹងពេកខ្ញុំដាំឆ្អិនបាយឆ្អិន
ទៅខ្ញុំបានវៃឆ្នាំចឹងទៅ

ក៖ នឹងអនុស្សាវរីយ៍ពូជាមួយឪពុកម្តាយ?

ខ៖ ដល់ពេលដែរវៃឆ្នាំចឹងទៅវៃឆ្នាំបានតែ2ដងម្តាយក្របួចសក់វៃហាស អត់បាយមួយល្ងាច

ក៖ បាទចឹងពូ?

ខ៖
បាទរហូតដល់ធំទៅមានប្រពន្ធអីចឹងទៅបែកបងបែកប្អូននឹកបងនឹកប្អូនណាស់លោកគ្រូអើយវាមិនដូចនៅក្មេងៗទេ កាលពីនៅក្មេងៗយើងឈ្លោះគ្នា ហើយយើងវៃគ្នាមែន

ក៖ ប៉ុន្តែយើងស្រលាញ់គ្នាណាពូ?

ខ៖ បាទយើងជួបជុំបងប្អូនគ្រាន់តែបែកបងបែកប្អូន
គ្មានបែកទៅណាឆ្ងាយទេនៅជិតៗនឹងគ្រាន់តែកាលនៅក្មេងយើងជួបជុំបងប្អូនយើងស្រលាញ់បងប្អូនរបស់យើង ពេលដែរបែកគ្នាអស់ចឹងទៅបែកគ្នាដូចកូនត្រីចឹងលោកគ្រូ

ក. បាទពូចុះបងប្អូនរបស់ពូនៅរស់ប៉ុន្មាននាក់ដែរពូ?

ខ៖ បានស្លាប់អស់2នាក់ហើយ

ក៖ ចឹងមានន័យថានៅរស់8នាក់?

ខ៖ នៅ8នាក់លោកគ្រូ

ក៖ ចុះដូចជាបងប្អូនរបស់ពូទាំង7នាក់នឹងពូ8នាក់ចឹង ពួកគាត់រស់នៅណាដែរពូ?

ខ៖ ពួកគាត់រស់នៅក្បែរៗខ្ញុំដែរនឹងលោកគ្រូ

ក៖ និយាយរួមទៅនៅភូមិនឹងទាំងអស់គ្នាតែម្តងអត់មាននរណាមួយនៅឆ្ងាយទេ?

ខ៖ នៅភូមិខុសគ្នា

ក៖
ប៉ុន្តែដូចជាអត់មាននរណាគេត្រូវការយកប្រពន្ធរឺមួយក៏យក៏យកប្តីទៅខេត្តផ្សេងៗអីទៀតអត់មានណាហីពូ?

ខ៖ បានមួយដែរទី4បានមានប្រពន្ធមកនៅតាខ្មៅនឹងស្លាប់
គាត់ាមានប្រពន្ធគាត់លែងលះគ្នានឹង
គាត់នៅជិតផ្ទះខ្ញុំដែរដល់ពេលគាត់មានប្រពន្ធហើយគាត់លែងលះគ្នានៅតាខ្មៅចឹងទៅគាត់ក៏ស្លាប់តែម្តងទៅ គាត់បានជំពាក់គេច្រើនពេក

កះ អូចឹងហោសពូ?

ខះ គាត់និយាយកូនមិនបានកូនចេះតែដើរលេង ហើយប្រពន្ធនឹងចេះតែលេងល្បែងលេងអីចឹងហាស គាត់បានស្រ្គេសគាត់ក៏ស្លាប់ចឹងទៅ ហើយបងប្អូនទាំងអស់គាត់មកពីភ្នំពេញចឹងទៅគាត់មករកតែខ្ញុំទេ គាត់ថាអូនអែងកាលពីអូនអែងនៅតូចៗនឹងបងៗធ្វើបាបណាស់នាំគ្នាវៃតប់ៗគ្នា ចឹងបានបងចេះតែស្រលាញ់ហែង បងចេះតែរត់មករកហែងទៅ ហើយខ្ញុំក៏និយាយថាអើយបងតើបងអែងគិតអីអារឿងនៅក្មេងនឹងយើងតែងតែទាស់គ្នាដល់ពេលដែរយើងមានប្រពន្ធយើងចេះតែនឹកនាគ្នាចឹងហើយ

កះ បាទត្រូវហើយពូ?

ខះ តែដល់ពេលដែរធំឡើងកុំអោយតែម៉ែឪពិបាកចិត្តអារឿងឈ្លោះគ្នាអី ថានៅតូចទៅវាតូច ដល់ពេលដែរធំឡើងនៅតែឈ្លោះគ្នាដដែល ដល់ពេលដែរមានប្រពន្ធកូនទៅនៅតែឈ្លោះគ្នាដដែលនឹងហោសកុំអោយមានចឹងអីកូនអើយ

កះ បាទត្រូវហើយពូ

ខះ ធ្វើម៉េចបើខំតែធ្វើបុណ្យទៅក្រែងជាតិនឹងបានជួបគ្នា និងជាតិក្រោយបានជួបគ្នាទៀតកូនអើយ បើមានមានក្រធ្វើម៉េចបើវាក្រ មានក៏វាអតែក្រក៏មិនដឹងធ្វើម៉េចដែរតែកុំអោយតែវាឈឺទៅបានហើយ

កះ បាទត្រូវហើយពូកុំអោយតែឈឺ

ខះ នឹងហើយត្រូវចឹងហើយ

កះ សុខភាពសំខាន់ណាពូ?

ខះ បាទត្រូវ

កះ ចុះម្តាយរបស់ពូមានឈ្មោះអីគេដែរពូ?

ខះ គាត់មានឈ្មោះ អិច អ៊ុន គាត់ស្លាប់បាត់ហើយគាត់អាយុ80ឆ្នាំ

កះ គាត់អាយុ80ឆ្នាំណាពូ?

ខ៖ អូគាត់អាយុ78ឆ្នាំ

ក៖ ប៉ុន្តែនៅពេលដែរកាត់ស្លាប់នឹងនៅឆ្នាំប៉ុន្មានដែរពូ មានចងចាំអត់ពូ?

ខ៖ នៅឆ្នាំ2016

ក៖ គាត់ស្លាប់នៅឆ្នាំ2016ចឹងមានន័យថាគាត់ឥឡូវប្រហែលជាអាយុ80ឆ្នាំមែនទេពូ?

ខ៖ បាទចឹងហើយលោកគ្រូ

ក៖ ចុះដូចជាឆ្នាំច័ន្ទគតិពូមានដឹងថាគាត់កើយនៅឆ្នាំអីគេទេពូ?

ខ៖ អត់ដឹងទេលោកគ្រូ

ក៖ លក្ខណះជូត ឆ្លូវ ខាល ថោះអីហាសពូ?

ខ៖ អត់ដឹងទេលោកគ្រូ

ក៖ អូចុះគាត់កើតនៅណាពូមានដឹងទេពូ?

ខ៖ អូអត់ច្បាស់

ក៖ ម្ដាយរបស់ពូហាសពូចាំទេ?

ខ៖ ទេអារឿងកើតនឹងដូចជាមិនសូវច្បាស់ទេលោកគ្រូ
ពីព្រោះអីឪរបស់ខ្ញុំស្រុកកំណើតរបស់គាត់នៅជិតព្រុំដែនវៀតណាមខាងកើតណ
ហើយគាត់មកនៅនឹងភូមិគ្រួសនឹង ភូមិចំបក ឃុំគ្រួសតាំងពីឆ្នាំណាអីឆ្នាំណាទេលោកគ្រូ
តាមម៉ែ តាមឪ តាមយាយ តាមតានឹង
ហើយម៉ែឪរបស់ខ្ញុំនឹងក៏គាត់មិនដែរនៅជិតគ្នាដែរគាត់នៅឆ្ងាយពីគ្នា

ក៖ បាទពូចឹង.....

ខ៖ ពេលដែរនៅជួបគ្នានឹងមិនដឹងជានៅឆ្នាំណាទេលោកគ្រូ

ក៖ អត់អីទេពូ

ខ៖ ខ្ញុំមិនសូវដឹងដែរនឹង

ក៖ ចុះឪពុករបស់ពូគាត់មានឈ្មោះអីគេដែរពូ?

ខ៖ គាត់មានឈ្មោះ សំ ខាន់

ក៖ ចុះគាត់អាយុប៉ុន្មានដែរពូឆ្នាំនឹង?

ខ៖ គាត់អាយុ88ឆ្នាំ

ក៖ ប៉ុន្តែគាត់នៅរស់សព្វថ្ងៃនឹងទេ?

ខ៖ គាត់នៅរស់ នៅជិះកង់ ជិះម៉ូតូ

ក៖ អូគាត់នៅសុខភាពរឹងមាំហោសពូ?

ខ៖
បាទគាត់ទៅវត្តទៅអីចឹងជិះម៉ូតូលឿនៗហាសដល់ពេលនឹងខ្ញើមកប្រាប់ថាអូឪទៅវត្តហើយ
គាត់ដួលម៉ូតូហាស ហែងមើលៗផងខ្លើអើយហា
អញ់ប្រាប់ថាឪអើយកុំជិះម៉ូតូលឿនៗពេកឪ ហើយឪថាមានលឿនអីប៉ុណ្ណឹងកូន

ក៖ អូគាត់និយាយចឹង?

ខ៖
នឹងហើយឪរបស់ខ្ញើកាត់កំព្រាតាំងពីតូចហោសម៉ែឪចុងគាត់ធ្វើបាបហោសគាត់អត់តែបា
យនឹង

ក៖ អូចឹងចុះ....

ខ៖ ហើយគាត់ប្រាប់ថាបានគាត់មិនអោយកូននៅនឹងគេ
កុំអោយកូនទៅណាឆ្ងាយកុំអោយកូនដូចឪកូនអើយ
ឪគេធ្វើបាបណាស់ម៉ែចុងបង្អត់តែបាយទេ

ក៖ អូត្រូវបាទពូ

ខ៖ កុំអោយកំព្រាដូចឪ

ក៖ បាទដូចជាឪពុករបស់ពូគាត់ធ្វើអីគេសំរាប់ចិញ្ចឹមជីវិតដែរពូ?

ខ៖ កាលពីគាត់នៅក្មេងគាត់រែកតែដី ហើយគាត់លីតែប៉ាវលោកគ្រូអើយ
គាត់លីស្រូវនៅនឹងគេ

កះ អូចឹងហោសពូ?

ខះ គាត់ធ្វើការគាត់រែកតែដីដើម្បីចិញ្ចឹមកូននឹង គាត់លីសែង

កះ ចុះគាត់ជាមនុស្សស្លូតរឺមួយក៏គាត់កាចដែរពូ?

ខះ គាត់ថាកាចទៅក៏ដូចជាមិនកាច តែថាគាត់ស្លូតទៅដូចជាមិនគាត់ទាស់សំដី បើនិយាយវិញបើថាមិនដែរមានមាត់លឺអីផងទេ ពេលដែរគាត់ដេកចឹងទៅខ្ញុំក៏លូនទៅដេកជិតគាត់ចឹងទៅគាត់ក៏ប្រាប់ពីប្រវត្តិគាត់

កះ អូគាត់ប្រាប់ពីប្រវត្តិគាត់?

ខះ បាទហើយខ្ញុំចូលចិត្តតែដេកជិតឪទេ ពីព្រោះម៉ែខ្ញុំមិនសូវដេកជិតម៉ែច្រើនតែញេញ ពីឬនាក់បងប្អូននឹងល្ងាចឡើងឈ្លោះគ្នាហើយ ឈ្លោះគ្នាដណ្តើមតែដេកជិតឪទេ

កះ អូចឹងហោសពូ

ខះ ពេលដែរឪដេកចឹងយើងមិនអាចដេកជិតសងខាងបានទេ

កះ អូបាទពូដោយសារតែ......

ខះ ដេកបានតែម្ខាងទេ

កះ ឪពុករបស់ពូគាត់គេងនៅជិតម្តាយរបស់ពូ?

ខះ បាទៗដេកតែជិតនឹងទាំងពីរនឹងគេញែកគ្នា ញែកអត់ដែរនៅជិតម៉ែទេដូចតែថាឪនៅម្ខាងចឹងពេលដែរឪសណ្តូកខ្លួនចឹងដេកបានតែខាងនឹងទេពីរនាក់នឹង ជួនកាលដេកចឹងមានអាបងមកលូនញែកដេកចឹងហាស

កះ ប៉ុន្តែសប្បាយ

ខះ ហើយអ្នកណាហ៊ានរករឿងខ្លាចត្រូវរំពាត់

កះ បាទពូ ចុះម្តាយរបស់ពូគាត់ធ្វើអីគេសំរាប់ចិញ្ចឹមជីវិតដែរពូ?

ខះ គាត់ធ្វើតែស្ទូងស្រូវហាសលោកគ្រូ

កះ គាត់ធ្វើតែស្ទូងស្រូវទេហោសពូ?

ខ៖ បាទគាត់ធ្វើតែចឹង

ក៖ បាទចុះគាត់ជាមនុស្សស្លូត រឺមួយក៏កាចដែរពូ?

ខ៖ គាត់ធម្មតាលោកគ្រូគាត់ស្លូតមិនស្លូត ហើយកាចមិនកាច
អើរអារឿងម៉ែនឹងកូនអារឿងរំពាត់ម៉េចនឹងត្រូវគ្នាយើងលេងច្រើនអីច្រើនហោស

ក៖ ចុះឪបុករបស់ពូគាត់មានធ្លាប់ប្រាប់ពីប្រវត្តិកាលពីគាត់នៅក្មេងៗទៅប្រាប់ពូអត់?

ខ៖ ប្រាប់ថាទៅនៅនឹងគេកូនអើយពិបាកណាស់នៅផ្ទះនោះ នៅផ្ទះនឹងស្លូតដាំបាយដាំទឹក
បាយទឹកអីនៅគេអោយបាយអោយតទឹកហូប បើនៅផ្ទះនោះគេកាចណាស់កូនអើយ
ថាមិនកាចទេគេស្អប់ឪ គេខឹងឪ គេប្រើឪ វង្វក់វង្វេងអីស្រេចតែគេ លឺគាត់ថានោះ

ក៖ អូបាទពូ

ខ៖ គេអើយទៅមើលគោពេលដែរមកពីមើលគោវិញ
បាយទឹកអីគេមិនគិតគូខំទៅធ្វើការនឹងក៏ធ្វើការហើយគេខឹងគេអីទៀតទៅលឺតែគេរអ៊ូលឺតែ
គេថាទេ ចឹងបានថាកុំអោយដូចឪកូនអើយ
កុំអោយកូនទៅនៅនឹងគេបិបាកស្រួលអីនៅអោបនឹងទ្រូងទៅ កុំអោយដូចគេថាស្លាប់បា
វាគ្រាន់ជាងស្លាប់មេ តែបើស្លាប់មេហើយគ្រាននរណាគេក្រប់គ្រងកូនទេ

ក៖ បាទត្រូវពូ

ខ. វាចឹងហាសលោកគ្រូ

ក៖ ចុះសំរាប់ម្ដាយរបស់ពូគាត់មានធ្លាប់ប្រាប់ពីប្រវត្តិគាត់កាលពីគាត់នៅក្មេងទៅពូអត់ពូ?

ខ៖ គាត់ប្រាប់ថានឹងម្ដាយគាត់ប្រាប់ថាគាត់នៅជាមួយយាយជាមួយតាហាស
ត្រូវតែបងវៃដែរ

ក៖ អូបងវៃដែរហោសពូ?

ខ៖ បាទគាត់លេងទឹក គាត់លេងទឹក ជិះបបោលអោយគោស៊ីស្រូវគេ ស្រូវអែង

ក៖ ហើយមកដល់ផ្ទះវិញគាត់ក៏វៃទៅ?

ខ៖ បាទគាត់ថាអ៊ុកូនអែងនឹងហាសកាចណាស់គ្មានពីណាកាចដូចទេកូនអើយ តាំងពីអោយម៉ែមើលគោតែម៉ែមើលគោអោយគោស៊ីស្រូវគេគាត់វៃម៉ែមិនដឹងអីទេអ៊ុំនឹង

ក៖ អូបាទពូចុះយាយតាខាងឪពុកពូមានចងចាំឈ្មោះគាត់ទេ?

ខ៖ ចាំតា

ក៖ ចុះគាត់មានឈ្មោះអីគេដែរយាយតាខាងឪពុកហាស?

ខ៖ ឈ្មោះយាយទុច តាយុត

ក៖ ប៉ុន្តែមួយនឹងខាងឪពុក?

ខ៖ ម៉ែឪខាងឪរបស់ខ្ញុំ

ក៖ ចុះខាងម្តាយ?

ខ៖ ហើយបើម៉ែឪខាងម្តាយរបស់ខ្ញុំវិញ ឈ្មោះតាប៊ុត យាយយឹម

ក៖ ចុះគាត់កើតនៅថ្ងៃខែឆ្នាំណាពូមានដឹងទេ?

ខ៖ អត់ដឹងទេលោកគ្រូ ហើយតាប៊ុត យាយយឹមនឹងម្តាយខាងម៉ែនឹងស្លាប់តា ហើយម្តាយខាងឪនឹងស្លាប់យាយ

ក៖ ចឹងនៅយាយមួយ នឹងតាមួយ?

ខ៖ បាទតាខាងម៉ែនៅយាយ ហើយតាខាងឪនៅឪស្លាប់យាយចុះដល់ពេលដែរគាត់ស្លាប់ទៅគាត់ថា តាខាងម៉ែចឹងហៅតាលង់មកចឹងទៅពឹងគ្នាថាតាលងៗស្រលាញ់គ្នានោះ

ក៖ អូបាទពូ

ខ៖ គ្មាននៅឆ្ងាយៗពីគ្នាអីថាតាលងអើយមើលយាយខ្ញុំផង បានប៉ុន្មានខែបានយាយនឹងតាជុំគ្នា

ក៖ ហាសកំប្លែងពូ?

ខៈ ដល់ពេលដែរដេកថ្ងៃខ្ញុំនៅកំលោះខ្ញុំដេកថ្ងៃនោះ តាលងអើយតាលងមើលយាយខ្ញុំផងតាលង បានមួយខែទៅពីរខែយាយតាលង

កៈ គាត់យកគ្នា?

ខៈ បាទដល់ពេលនឹងទៅឪរបស់ខ្ញុំគាតលួចសើច

កៈ រឿងកំប្លែងហាសពូ

ខៈ ឪរបស់ខ្ញុំគាត់ចេះតែលួចសើច

កៈ ចុះយាយតាខាងឪពុកនឹងខាងម្ដាយពូមានដឹងថាពួកគាត់កើតនៅណាអត់ពូ?

ខៈ អត់ដឹងទេលោកគ្រូ

កៈ ប៉ុន្តែគ្រាន់តែពូដឹងថាពេលដែរពូកើតមកគឺពូនៅណុងតែម្ដងនឹង?

ខៈ បាទលោកគ្រូនៅនឹងយាយតា

កៈ ចុះសំរាប់ពូទៅរស់នៅខេត្តស្វាយរៀងយូរនៅពូ?

ខៈ តាំងពីដឹងក្ដីមកគឺខ្ញុំនៅខេត្តស្វាយរៀងនឹងតែម្ដងនឹង

កៈ ចឹងមានន័យថាប្រហែលជាខ្ទង់ជិត50ឆ្នាំហើយណាពូ?

ខៈ បាទគឺកើតនៅតែភូមិនឹង កើតនៅនឹងដឹងនៅនឹងតែម្ដងលោកគ្រូ

កៈ អូចុះពូមានបងប្អូនណា រឺមួយក៏សាច់ញ្ញាតិណាដែរទៅនៅក្រៅប្រទេសអត់ពូ?

ខៈ ទេលោកគ្រូ

កៈ ដូចជាថៃ វៀតណាមអីមានអត់ពូ?

ខៈ ទេគ្មានទេលោកគ្រូ

កៈ ព្រេងអង្គរក៏អត់មានដែរណាពូ?

ខៈ អត់មានទេ

កៈ ចុះភរិយាយរបស់ពូគាត់មានឈ្មោះអីគេដែរពូ?

ខ៖ គាត់ឈ្មោះសំ នាង

ក៖ ឈ្មោះ សំនាង ចុះពូរៀបអាពាហ៍ពិពាហ៍នៅពេលណាដែរពូ?

ខ៖ ថាម៉េច?

ក៖ រៀបអាពាហ៍ពិពាហ៍ជាមួយមីងហាស?

ខ៖ នៅឆ្នាំ2000ទេនៅឆ្នាំកៅប៉ុន្មានទេនេះដូចជាឆ្នាំ1994ទេហី

ក៖ ប៉ុន្តែពូរៀបអាពាហ៍ពិពាហ៍នឹងប៉ុន្មានឆ្នាំហើយពូ?

ខ៖ កាលពីមុនចេះដកតែតឡូវលែងចេះ

ក៖ ចឹងអស់23ឆ្នាំ?

ខ៖ ចឹងហើយ

ក៖
ចុះនៅពេលដែរពូរៀបអាពាហ៍ពិពាហ៍នឹងតើពូជាអ្នករៀបដយចិត្តអែងរឺមួយក៏ម្តាយឪពុកជាអ្នករៀបចំអោយពូដែរ?

ខ៖ ឪពុកម្តាយជាអ្នករៀបចំអោយ

ក៖ ប៉ុន្តែមានជាជំនូនអោយទៅមីងអីអត់ពូ?

ខ៖ មានតាលោកគ្រូ មានតិចតួច

ក៖ មានដូចជាប៉ុន្មានដែរអាចប្រាប់បានទេពូ?

ខ៖ កាលណុងគេគិតមាសហាសលោកគ្រូជូនកាលគេអោយ1ជីចឹងទៅ
ជូនកាលផ្ទះខ្លះគេមានចឹងទៅគេអោយគេបង្កាប់5ជីចឹងទៅ
ខ្លះគេមិនបង្កាប់ទេគេថាអោយតែយល់ចិត្តនឹងចិត្តមានរឺមិនមានអីគេមិនគិតទេពេលដែរបានកូនថៅទៅគេចេះរកស៊ីហើយ

ក៖ បាទត្រូវហើយពូ

ខ៖ ខ្លះគេថាថ្លៃទឹកដោះចឹងជូនគេទៅតិចតួចជូនកាលខោអាវមួយកំប្លេចឹងទៅ

កៈ ចុះពូមានចងចាំពេលដំបូងពូអាចប្រាប់ខ្ញុំបន្តិចបានទេថាពូជួបមីងនៅពេលណា ហើយហេតុអីបានជាពូស្រលាញ់មីងចឹង ដូចជាពូជួបមីងនៅពេលណា ហើយពូលួចស្រលាញ់មីងប៉ុន្មានឆ្នាំដែរហើយពូ?

ខៈ ខ្ញុំម៉ែឪបង្ហាត់បង្ហាញខ្ញុំចាប់ផ្ដើមមានចិត្តហើយ បាទមានចិត្តចឹងទៅ

កៈ ប៉ុន្តែមានអនុស្សាវរីយ៍អីជាមួយគ្នាប៉ុន្មានខែ ប៉ុន្មានឆ្នាំបានពូទៅចូលស្ដីចឹងហាស?

ខៈ អត់មានអនុស្សាវរីយ៍អីទេលោកគ្រូ ខំអីក៏មិនដែលបានឃើញប្រពន្ធរបស់ខ្ញុំដែរ ហើយពេលដែរទៅដណ្ដឹងហើយចឹងទៅជួបប្រពន្ធរបស់ខ្ញុំក៏អត់ស្គាល់គ្នាដែរនឹង

កៈ ចឹងហោសពូ?

ខៈ ខ្ញុំមិនដែរបានឃើញមុខប្រពន្ធរបស់ខ្ញុំទេ

កៈ ទៅដណ្ដឹងម៉េចចឹងពូ?

ខៈ ទៅដណ្ដឹងទៅដណ្ដឹងទាល់តែដល់ថ្ងៃការ

កៈ គ្រាន់យើងទៅដណ្ដឹងខាងស្រីនឹងខាងប្រុសគេឃើញគ្នាហីពូ?

ខៈ ឃើញប៉ុន្តែទៅណាអីទៅណាពេលដែរបានជួបគ្នាអត់មានស្គាល់គ្នាទេ?

កៈ អូយើងឃើញគ្នាតែមួយភ្លែតហោសពូ?

ខៈ បាទយើងឃើញគ្នាចំងាយមួយគីឡូដីអីនឹងហាស តែបើធ្វើបុណ្យធ្វើទាន់អីជួបគ្នាអត់ដែរស្គាល់គ្នាទេនឹង តែបើប្រពន្ធខ្ញុំគាត់ស្គាល់ខ្ញុំ

កៈ ប៉ុន្តែគាត់ហៅពូទៅ?

ខៈ ប្រពន្ធរបស់ខ្ញុំហៅខ្ញុំ

កៈ ចឹងសំរាប់ពូចេះអានរឺមួយក៏ចេះសរសេរអក្សរខ្មែរបានល្អប៉ុណ្ណាដែរពូ?

ខៈ
ខ្ញុំមិនសូវបានរៀនបានខ្ពង់ខ្ពស់ទេលោកគ្រូអើយពីព្រោះអីជីវភាពរបស់ខ្ញុំទន់ខ្សោយណាស់

កៈ ប៉ុន្តែរៀនបានថ្នាក់ទីប៉ុន្មានពូ?

ខ៖ ថ្នាក់ទី3នឹង

ក៖ ថ្នាក់ទី3ចឹងមានន័យថាកាលពីជំនាន់ណុងរៀនបានថ្នាក់ទី10មែនទេពូ?

ខ៖ អត់បានរៀនសូត្រលោកគ្រូអើយពីព្រោះយើងពិបាកជីវភាព

ក៖ អូបាទពូចឹងកាលពូរៀននឹងនៅសាលាបឋមនឹងនៅណាវិញពូ?

ខ៖ នៅស្រុក

ក៖ នៅស្វាយជ្រុំនឹងតែម្តងហោស?

ខ៖ បាទនៅស្វាយជ្រុំ

ក៖ ប៉ុន្តែសាលានឹងមានឈ្មោះអីគេដែរពូ?

ខ៖ នៅសាលាបឋមសិក្សាពោធំ

ក៖ នៅសាលាពោធំណាពូ?

ខ៖ នៅអនុវិបឋមសិក្សាពោធំប៉ុន្តែ កាលខ្ញុំរៀននឹង នៅឃុំគ្រួស
ប៉ុន្តែខ្ញុំរៀននឹងរៀននៅឃុំចំបក

ក៖ អូនៅឃុំចំបកណាពូ ចុះពូមានចេះភាសាអីក្រៅពីភាសាខ្មែរទេពូ?

ខ៖ ទេលោកគ្រូ

ក៖ ពូចេះភាសាវៀតណាមអត់ពូ?

ខ៖ អត់ចេះទេលោកគ្រូ

ក៖ ចុះពូមានមិត្តភក្តិណាដែរធំធាត់មកជាមួយគ្នាអត់ពូ?

ខ៖ មានច្រើនណាស់លោកគ្រូពួកម៉ាក់

ក៖ ចុះមានឈ្មោះអីគេខ្លះដែរពូអាចរៀបរាប់តិចតួចបានទេពូ?

ខ៖ ឈ្មោះ សុំ សារ៉ាក់, ចាន់ សារ៉ាត់, វែន ៣៧, មាស មូន្នី, មូក នី

កៈ
ចុះពូមានចងចាំថាធ្លាប់មានអនុស្សាវរីយ៍រឺមួយក៏មានធ្លាប់លេងអីជាមួយគ្នាជាមួយពួកគាត់
អត់ពូ ដូចជាអ្វីមួយដែរយើងគិតថាចងចាំជាមួយពួកគាត់ហាស
ដូចជាទៅលេងទឹកអីជាមួយគ្នា
រឺមួយក៏ដើរលេងស្រែអីជាមួយគ្នាអីចឹងហាសពូដែរយើងគិតថាចងចាំហាស?

ខៈ ទៅបាចឌីកាលណុងអត់មានផ្ទះទេប្រជាជនអីទេនៅឆ្ងាយណាស់

កៈ បាចឌីហោសពូ?

ខៈ បាទបាច់ឌី

កៈ ចុះបាចឌីនឹងយ៉ាងម៉េចទៅពូ?

ខៈ បើនៅនឹងគេហៅអន្លុង

កៈ គេហៅអន្លុង?

ខៈ ដូចថានៅប៉ុនមួយគ្រែចឹងហាស គេហៅបាចត្រីនឹងហាស

កៈ អូចឹងទេហោសពូ?

ខៈ នឹងហើយគេជីកជំរៅនឹងចឹងហាសមានដើមចេកអីមួយៗ

កៈ អូបាទៗពូធ្វើម៉េចទៅ?

ខៈ ចេះតែនាំគ្នាបាចចឹងទៅ ហើយហូបបាយអីចឹងទៅ ហើយក៏ដកមេដកអីចឹងទៅ

កៈ អូសប្បាយពូ?

ខៈ បាទហើយគេសួរគ្នាហើយថាហែងនរណាការមុន
ហើយហាសអញ់ទៅដណ្តឹងគេយ៉ាងម៉េចហាសអញ់ខ្មៅចឹងហាសគេមិនយកអញ់ទេហើយ
គេនិយាយវាមិនដែរទេហាសហែងសហែងទៅដណ្តឹងទៅហាស
ហេអញ់មិនហ៊ានទៅទេហាសគេមិនទៅស្តីអញ់ផងនឹង

កៈ ពូនិយាយាជាមួយមិត្តភក្តិរបស់ពូ?

ខ៖ បាទថាហែងស្រលាញ់កូនម្នាក់ណុងហើយ
អញ់អោយឪរបស់អញ់ទៅដណ្តឹងហើយហាស អើរបើហែងទៅដណ្តឹងអញ់យល់ព្រម
តែបើក្រៅពីនឹងអញ់មិនយល់ព្រមទេ

ក៖ ហាសពូបាទពូ

ខ៖ ថាហែងទៅដណ្តឹងម្នាក់ណុងទៅអញ់ចិត្តស្លូតបូតណាស់ហាស
ហឺអញ់ខ្លាចគេជេណាស់ហាស
ហើយពួកម៉ាក់ណុងវាមានពួកម៉ាក់ផ្សេងចឹងហាសខ្ញុំអត់ស្គាល់ទេ
វាស្រលាញ់គ្នាពួកម៉ាក់ពេក
ពួកម៉ាក់ថាមើលពួកម៉ាក់ហែងទៅមើលប្រពន្ធអញ់តិចមើលពួកម៉ាក់មើលពួកម៉ាក់ហែងត្រូវ
ចិត្តទេហា

ក៖ អូចឹងម៉េចទៅ?

ខ៖ អញ់ក៏ត្រូវចិត្តដែរហាសហើយហែងទៅមើលៗបើហែងត្រូវចិត្តហើយនៅអី
ទោះចឹងអញ់នាំទៅមើលទៅបាយទឹកផ្ទះរបស់គេ
ហើយនាំពួកម៉ាក់នឹងទៅបាយទឹកផ្ទះរបស់គេ

ក៖ ផ្ទះមីងហោសពូ?

ខ៖ អត់ទេនិយាយក្រៅតា

ក៖ អូចឹងហៅហោសពូ?

ខ៖ ពួកម៉ាក់របស់ខ្ញុំនឹងវាមានពួកម៉ាក់វាផ្សេង ហើយបាននាំពួកម៉ាក់ផ្សេងនឹង

ក៖ អោយទៅស្គាល់គេទៅ?

ខ៖ អោយទៅស្គាល់ប្រពន្ធ គេទៅដណ្តឹងហោស
ទោះទៅមើលៗហាសអាបួកម៉ាក់ថាហីប្រពន្ធហែងស្អាតណាស់ហាស
ទោះមកវិញហាសពេលដែរជិះកង់មកដល់ផ្ទះ
អាពួកម៉ាក៏នឹងអោយឪគេទៅដណ្តឹងអាពួកម៉ាក់ក៏អត់ទៅ

ក៖ ចឹងអត់ទៅ?

ខ៖ នឹងបានអាពូកម៉ាក់ក្រោយនឹងទៅ

ក៖ អូកំប្លែងពូ

ខ៖ អោយហៅអាពូកម៉ាក់ទៅមើលប្រពន្ធប៉ែជាអោយម៉ែឪទៅដណ្តឹងគេទៅ

ក៖ អូកំប្លែងណាស់ពូ

ខ៖ តាមការពិតលោកគ្រូ

ក៖ បាទៗពូប៉ុន្តែវាគួរអោយកំប្លុកប្លងហាសពូ

ខ៖ រឿងពិតលោកគ្រូ

ក៖ ចុះពូមានធ្លាប់ទៅធ្វើការនៅវាលស្រែអត់ពូ?

ខ៖ ធ្លាប់តា

ក៖ ធ្លាប់ទៅដកស្ទូងអីទេ?

ខ៖ ធ្លាប់ដកស្ទូងអីទៅជួយ ដល់ពេលដៃរដកៗហើយចឹងទៅនាំគ្នា
ពូកម៉ាក់នឹងទៅរែកខ្លះទៅរែក ខ្លះទៅលីនង្គ័ល ខ្លះដឹកក្របីដេញក្របី
ជួនកាលទៅដេកចាំអន្លុងចាំយកទាំងអស់គ្នា
ហើយយកស្រាទៅផឹកហើយថាយើងហាសបើសិនជាមានកូនហាសនាំគ្នា
កុំបែកបាក់គ្នាណានៅតាមរាប់ក្នុរហូតណាស់ពូកម៉ាក់ណាស់

ក៖ ពូសន្យាគ្នាមែនពូ?

ខ៖ គ្រាន់តែយើងនិយាយគ្នានឹងហាសហែងហាសបើអញ់អញ់មិនចោលខ្លាងែងទេហាស
នឹកឃើញអនុស្សាវរីយ៍ហោស មែនលោកគ្រុពេលដៃរបានទៅជុំគ្នារត់ទៅអោបគ្នាយំហើយ

ក៖ អូបាទចឹងហោសពូ?

ខ៖ ខ្ញុំរត់ទៅអោបខ្លាអែង ខ្លអែងទៅរកស៊ីនៅណា
អើយខ្លាអើយអញ់ទៅរកស៊ីឆ្ងាយណាស់ខ្លអើយ អញ់ទៅតាមប្រពន្ធរបស់អញ់ហាសអើយ
អញ់ទៅតាមប្រពន្ធរបស់អញ់ទៅរកស៊ីអើយចុះហោងអាសាមកអើតៗអញ់ផងហាស
កាលដៃរប្រពន្ធរបស់អញ់ឈឺអី ជួនកាលពូកម៉ាក់នោះផ្សេងចឹងទៅ

កៈ ជួបពួកម៉ាក់ច្រើនណាពូ?

ខៈ
នឹងមួយនឹងហាសដល់ពេលពួកម៉ាក់ផ្សេងដល់គ្រប់អោបសួរវាថាខ្លាហែងនៅណាហាអា
នោះវាមានស្តីអី និយាយហើយនាំគ្នាហូរទឹកភ្នែក ថានឹកស្មានមិនដល់ទេខ្លួអើយ
នឹកស្មានមិនដល់ទេយើងបែកគ្នាយូរហើយនឹកមិនស្មានថាមិនដល់ថាបានជួបគ្នានៅថ្ងៃនឹង
ទេណាជួនកាលពួកម៉ាក់វាផ្សេងទៀតវាថា អេសំ សារឿន លឺចឹងឈប់មើល
ថាហែងពីណាគេ?

កៈ មិត្តភក្តិពូសួរទៅ?

ខៈ ថាអើរអែងនឿនហាស ថានឿននៅណាវិញថានៅព្រៃចំបកអូ
ជួនកាលរឿនហេស្គាល់ខ្ញុំទេ ថានៅណាវិញថានៅពោធិរាជ អូនៃវ៉ាន់ហោស
អូនឹងហើយបានរត់ទៅអោបគ្នា

កៈ អូប៉ុន្តែសុទ្ធតែមិត្តភ្តិជិតស្និទ្ធិនឹងគ្នា?

ខៈ នឹងហើយសួរថាសុខសប្បាយអីអត់អើរឥឡូវបានធ្វើប៉ូលីស
អូបានធ្វើប៉ូលីសអូអញ់អរគុណហើយហាស
ថានៅតែអែងទេអែងនៅតែស្រែកាន់តែកន្ទុយនង្គ័លទេ

កៈ នង្គ័លគោ?

ខៈ នឹងហើយហែងកាន់កន្ទុយនង្គ័លគោកុំបាច់ទឹកគោប្រយ័ត្នគោធាក់ហែង

កៈ អូបាទពូ

ខៈ អូអត់អីទេបើគោធាក់អញ់រងវិញហាស

កៈ ចុះសំរាប់ពូមានធ្លាប់ចិញ្ចឹមគោ មាន់ទា ជ្រុកអីអត់ពូ?

ខៈ ច្រើនហាសលោកគ្រូចិញ្ចឹមមាន់ ទាអីនឹង

កៈ ចិញ្ចឹមលក្ខណៈកសិដ្ឋាន រឺមួយក៏

ខៈ យើងលក្ខណៈចិញ្ចឹមជាច្រើនដែរ

កៈ រឺមួយក៏ចិញ្ចឹមលក្ខណៈជាគ្រួសារថា ចិញ្ចឹមអានេះបន្តិច រឺអានោះបន្តិចចឹងហាសពូ?

ខៈ បាទៗខ្ញុំចិញ្ចឹមថាកាលពីមុនខ្ញុំមកភ្នំពេញខ្ញុំចិញ្ចឹមលក្ខណៈមេជ្រូក3ក្បាលហាស ខ្ញុំធ្វើតែស្រាទេ ដល់ពេលដែរខ្ញុំបានជំពាក់គេ ជំពាក់អែងពេលដែរខ្ញុំពិបាកចិត្ត ខ្ញុំលក់អស់ទៅខ្ញុំលក់យកសងអង្គការអង្គរដ្ឋអីនឹង ថាទាន់ខ្ញុំសងគេអោយអស់ ពេលដែរសងគេអស់នាំប្រពន្ធមកដល់ភ្នំពេញ
បេលដែរមកដល់ភ្នំពេញក៏សងគេតិចៗចឹងទៅណា

កៈ អូបាទចឹងពូ?

ខៈ បាទកាលពីមុនបានខ្ញុំពិបាកចិត្តមែន
ធម្មតារឿងពិបាកចិត្តនិយាយមិនដែរបានស្រួលទេលោកគ្រូអើយនិយាយ10ម៉ាត់ត្រូវ1ម៉ាត់អីនឹងហាស

កៈ អូត្រូវពូ

ខៈ ចឹងបានយើងវាមានកើតមកមានគោលចំណាងអីបានវាល្អហាសកាលណុង
យើងកើតមកវាពិបាកចឹងខួរក្បាលយើងវាមិនសូវនឹងទេ

កៈ ចុះសំរាប់ពូតើពូចូលចិត្តម្ហូបអីគេដែរពូ ដែរពូគិតថាពូចូលចិត្តហាសដូចជា សម្លម្ជូរ ស្ងោរ ចៀន ឆាអីចឹងហាសតើពូគិតថាម្ហូបអីដែរពូចូលចិត្តជាងគេដែរពូ?

ខៈ ខ្ញុំចូលចិត្តជាងគេតែហូបម្លូកហូបអីចឹង

កៈ លក្ខណៈថាម្លូកជាមួយស្វាយខ្ចីអីចឹងហាសពូ?

ខៈ បាទម្លូកចឹង

កៈ នេះកូនពូដែរ?

ខៈ កូនធិមតា

កៈ អូកូនធិមហោស?

ខៈ គេការខែក្រោយហើយ

ក៖ អូឡូយដែរតា

ចុះពូចូលចិត្តលេងល្បែងប្រជាប្រិយ៍អីដែរថាពូចូលចិត្តលេងតាំងពីក្មេងហាសដូចជាចោលឈូង ទាញព្រាត រឺមួយក៏លាក់កន្សែងអីចឹងហាសពូ?

ខ៖ នឹងដាក់ទទឹមគ្នា

ក៖ ចូលិចិត្តលេងទាំងអស់?

ខ៖ បាទៗដាក់ទទឹមគ្នានឹង អត់លេងតែបៀរទេ អត់លេងបៀរទេគិតថាលេងល្បែងវាមិនល្អ ល្បែងលេងទៅអស់លុយវាមិនស្រួលទេ

ក៖ ចុះពូមានចងចាំបទចំរៀងណាដែរពូមានចេះតាំងពីក្មេងរហូតមកដល់ពេលនេះអត់ពូ?

ខ៖ ខ្ញុំច្រៀងបទពិដើមច្រៀងបានតែក្បាលបន្តិចនឹង

ក៖ ប៉ុន្តែបទអីគេវិញពូចំណាងជើងហាសពូមានចងចាំទេពូ?

ខ៖ បើមានមនុស្សដើរចឹងចេះតែមានហូហែចឹងទៅ

ក៖ ប៉ុន្តែពូមានចងចាំថាអូបទស្អីគេមួយពីដើម

ដូចជាចំណាងជើងបទចំរៀងអីមួយពូមានចងចាំទេពូ?

ខ៖ បទរសៀលគងភ្នំ

ក៖ អូបទរសៀលគងភ្នំ អូបទព្រាប សុវត្តិហោស?

ខ៖ មិនមែនទេបទ លោក កែវ សារ៉ាត់តាលោកគ្រូ

ក៖ ពូអាចដាក់មួយឃ្លាអោយកូនបានស្តាប់បានទេពូ?

ខ៖ ហើយបទអីណៃធ្វើបុណ្យដាក់បាទ ចំណាងជើងវាហាស

ក៖ អូធ្វើបុណ្យដាក់បាទ?

ខ៖ ចំណាងជើងវាសន្សំកុសល

ក៖ ខ្ញុំភ្លេចបាត់ហើយពូ?

ខ៖ ជីវិតក្មេងវត្ត

កៈ អូជីវិតក្មេងវគ្គហោស
ចុះពូគិតថាតាំងពីក្មេងរហូតមកដល់ពេលនេះពូគិតថាជីវិតរបស់ពូមានការផ្លាស់ប្តូរអីគេខ្លះដែរពូ?

ខៈ មានការផ្លាស់ប្តូរកាលពីនៅក្មេងវាពិបាកលោកគ្រូ យើងមិនដែរបានស្គាល់លុយស្គាល់កាក់អីទេ ដល់ពេលដែរមានប្រពន្ធ អាចមានដឹងឃើញនៅស្រូវអង្ករអីនឹងគ្រាន់បានហូបឆ្អែតព្រឹកល្ងាចចឹងទៅ ហូបតែបបរលោកគ្រូអើយ ខ្ញុំទើបតែស្គាល់បាយនៅឆ្នាំ1990នឹង

កៈ បាទពូបាទចឹងហោស?

ខៈ ខ្ញុំដឹងក្តីឡើងស្គាល់តែបបរទេលោកគ្រូអើយ ខ្ញុំចែកគ្នាបានតែបន្តិចៗម្នាក់នឹង ហើយបើខ្ញុំឡើងទៅក្អួតនៅម៉ោង1ម៉ោង2ចឹងឪទឹកភ្នែកហើយ ឡើងក្អួតចុកល្វលនោះលោកគ្រូ

កៈ ចុះនៅក្នុងក្រុមគ្រួសាររបស់ពូរឺមួយនរណាគេម្នាក់ដែរចេះលេងឧបករណ៍ភ្លេងអត់ពូ?

ខៈ ទេលោកគ្រូ

កៈ អត់មាននរណាគេចេះទេណាពូ?

ខៈ បាទអត់ទេ

កៈ ចុះបងប្អូនកូនក្មួយ កូនធិមអីអត់មាននរណាគេចេះទេលេងភ្លេងទេ?

ខៈ ទេលោកគ្រូ

កៈ
អត់ចេះទេណាពូចុះផ្ទះរបស់ពូមានលក្ខណៈបែបណាទាំងពីក្មេងរហូតមកដល់ពេលនេះហាស ដូចថាពីក្មេងផ្ទះយ៉ាងម៉េច ហើយឥឡូវផ្ទះយ៉ាងម៉េចចឹងហាសពូ?

ខៈ ដូចថាកាលនៅពីក្មេងផ្ទះកំពស់នេះពីដីហាសលោកគ្រូ ហើយគេប្រើឬស្សី ហើយប្រកចំបើង ហើយដល់ពេលឥឡូវគេធ្វើសុទ្ធតែបាតុង ហើយជញ្ជាំងស័ង្កសីរឺមួយក៏ក្តារអីចឹងទៅ រៀបឥដ្ឋក្រោមផ្ទះដាក់ឥដ្ឋការ៉ូអីចឹងទៅថាបានស្រួលចឹងដែរលោកគ្រូ

ហើយកាលពីដើមនឹងគ្មានកង់ទេទៅខ្ចីកង់គេនឹងពេលដែរអោយគេវិញទាល់តែដុះលាងអោយជ្រះបានអោយគេវិញតែឥឡូវបានស្គាល់ម៉ូតូ

ក៖ អូបាទពូចឹង……

ខ៖ ហើយពេលដែរមកភ្នំពេញម្តងចង់ជិះឡានណាស់លោកគ្រូ បើបានអង្គុយលើឡានបន់អោយតែគេទៅទេ ទៅមើលឡានគេជិះយ៉ាងម៉េចអីយ៉ាងម៉េច

ក៖ តែឥឡូវវាសាំហើយជិះទៅជិះមករាល់ថ្ងៃហើយ?

ខ៖ ឥឡូវសាំលែងចង់ជិះឡានហើយ ចង់ជិះម៉ូតូម្តងស្រេចតែចិត្តទេលោកគ្រូ

ក៖ ចុះផ្ទះរបស់ពូដូចជាពូជាអ្នកសាងសងដោយខ្លួនអែងរឺមួយក៏ជួលគេ ដូចថាពូអោយគេជួយធ្វើអោយរឺមួយក៏យ៉ាងម៉េចចឹងហាស?

ខ៖ ខ្ញុំអើរធ្វើ……..

ក៖  កាលពីនៅក្មេងរហូតមកដល់ពេលនេះហាសពូ?

ខ៖ ខ្ញុំជួលគេហាសលោកគ្រូ

ក៖ ជួលគេចឹងមានន័យថាយើងជួលគេអោយនធ្វើអោយយើង ហើយយើងអោយលុយទៅគេ?

ខ៖ បាទៗជួលគេនឹង

ក៖ ចុះពូមានដឹងថាផ្ទះរបស់ពូមានសំភារះអីសំរាប់សាងសងផ្ទះរបស់ពូដែរទេពូ?

ខ៖ គេប្រើឈើលោកគ្រូនៅខាងក្រោមមានបាយតុង

ក៖ ប៉ុន្តែសំរាប់សាងសងវាមានដូចជាគ្រឿងអីទេដូចជាដែកគោល អីគេខ្លះដូចជាពូថៅញញួរអើចឹងហាសមានអីផ្សេងពីនឹងទៀតទេពូ ដូចជាមានដែកឈូសដែរហោសពូ?

ខ៖ មានដែកឈូស

ក៖ មានដែកថាបដែរមែនពូ?

ខ៖ មានរណា មានដែកថាប មានដែករ៉ មានដែកខួង

កៈ មានដែកគាស់ដែរមែនពូ?

ខៈ បាទមានដែកគាស់ ដែកខ្វង ហើយមានស័ង្កសីជំបូល ប្រកជញ្ជាំងអី មានរនាបដែរគោល

កៈ រនាបស័ង្កសីយើងនឹងមែនពូ?

ខៈ បាទមានរនាប គេហៅស័ង្កសីពីងពួងអីចឹងហាស

កៈ ចុះពូគិតថាជំនាញអីដែរពូគិតថាពូចេះស្ទាត់ជំនាញតែម្តងហាស ពូគិតថាអូជំនាញមួយនឹងពូចេះស្ទាត់តែម្តងអាចធ្វើ រឺក៏ចេះឪពុកម្តាយបង្រៀនធ្វអីចឹងហាសលក្ខណៈថាដូចជាវេញវល្លិ៍ ធ្វើផ្តៅ រឺក៏ដេរកន្ទេល រឺដេរក្រម៉ា រឺធ្វើក្រម៉ាអីចឹងហាស?

ខៈ អត់ចេះទេលោកគ្រូពីព្រោះអីម៉ែឪគាត់ល្ងង់នឹង

កៈ ចេះពូគិតថាជំនាញអីដែរពូគិតថាពូចេះខ្លួនឯងតែម្តងនឹង ឥឡូវពូគិតថាសព្វថ្ងៃនឹងពូចូលចិត្តធ្វើអីជាងគេដែរ លក្ខណៈថាលក់ដូររឺមួយក៏អីចឹងហាស?

ខៈ ខ្ញុំចូលចិត្តតែលក់ដូរលោកគ្រូ

កៈ លក់ដូរហោសពូ?

ខៈ ដូចតែលាសនឹង ដូចលាសនឹងអាចទៅលក់ទៅអីបាន បើថាអោយធ្វើអីអោយខុសពីនឹងដូចជាអោយទៅធ្វើសំណង់រឺមេយយក៏រៀបឥដ្ឋអីអោយគេ មិនចេះទេបានត្រឹមតែលាយកំបោអោយគេបាន

កៈ នឹងជាជំនាញរបស់ពូណា?

ខៈ បាទៗហើយអូសស៊ីម៉ង់ លើកស៊ីម៉ង់លើកកំបោលើកអី ឥដ្ឋការ៉ូលើកថ្មនឹងខ្សាច់អីលើកអោយគេបានលោកគ្រូ តែបើអោយធ្វើខ្លួនឯងតែម្តងទៅមិនរួចទេ ខ្ញុំមិនចេះទេទើបតែស្គាល់ភ្នំពេញនឹងហាសបានមកលក់លាសនឹងហាស

កៈ ចុះពូអាចប្រាប់ពីពេលណាដែរពូគិតថាជាពេលដែរលំបាករបស់ពូហាស ដែរពូគិតថាលំបាកតាំងពីក្មេងរហូតមកដល់ពេលនេះហាស?

ខ៖ តាំងពីដឹងក្ដីឡើងស្រុកសង្គ្រាមតែម្ដងហាសលោកគ្រូ

ក៖ ចឹងមានន័យថាពេលដែរពូលំបាកជាងគេគឺមានស្រុកសង្គ្រាមពលពត?

ខ៖
បាទស្រុកសង្គ្រាមរហូតពេលដែរបែកនៅក្នុងឆ្នាំ1980នឹងបានស្រួលមែនបានជុំម៉ែជុំឪមែន
តែ ពេលដែរស្គាល់ម៉ែឪច្បាស់នៅឆ្នាំ1983

ក៖ អូចឹងហោសពូ?

ខ៖
នឹងស្គាល់ច្បាស់ហើយកាលពីមុនកាលនៅតូចៗរត់តែតាមគេនឹងរាល់តែបងទៅចាប់ដឹងៗ
ថាបងទៅចាប់ថាអាអូនម៉ែគេទេ

ក៖ អូច្រឡំម៉ែណាពូ?

ខ៖ បាទច្រឡំម៉ែច្រឡំឪហើយដល់ពេលដែរបែកហើយនឹង ហើយមិនដល់គេហៅនយោធា
ពេលដែរនយោធាចឹងបងប្រាប់ថាអាអូនហែងយកការកាលណុងការពីដើមហាស

ក៖ បាទពូចឹង......

ខ៖ ថាហែងយកអានឹងទៅអោយម៉ែដាក់មុខអោយទៅអាអូន
ដល់ពេលដែរទៅដល់ឃើញម៉ែគេក៏យកទៅដាក់ ពេលដែរយកទៅដាក់គេដាក់តែកូនគេ
ពេលដែរមកដល់ផ្ទះប្រាប់បងថាបងហាសម៉ែមិនដាក់អោយទេបង
ហើយបងថាម៉ែណាមិនដាក់អោយហាសម៉ែអោយទៅតាអាអូន
ថាម៉ែមិនដាក់អោយផងម៉ែដាក់អោយតែកូនគេនឹង
ពេលដែរម៉ែមកនឹងថាម៉ែអែងអត់ដាក់អោយខ្ញុំទេ ថាមិនមែនម៉ែទេម៉ែគេទេ

ក៖ ចុះពូឆ្លងកាត់ការលំបាកនឹងដោយរបៀបណាដែរពូ?

ខ៖ គ្មានពិបាកអីទេលោកគ្រូគ្រាន់តែជីវភាពរបសយើងគឺគ្មានតែម្ដងនឹង

ក៖ អូចឹងហាសពូ?

ខ៖ គ្មានបាយគ្មនទឹកងីចឹងហាសលោកគ្រូ

ក៖ បាទពូចុះពូ.....?

ខ៖ នៅជុំបងប្អូន
ជុំម៉ែជុំឪមែនតែម៉ែឪមិនដែរបានធ្វលើបាបរឺក៏ធ្វើទុកអីមកលើយើងទេគាត់គ្មានទៅវៃតប់អីទេ គ្រាន់តែជីវភាពរបស់យើងអង្កគ្មានដាំអីចឹងហាសលោកគ្រូ
អង្ករគ្មានដាំយើងទៅបបរចឹងទៅចែកគ្នាហូបទៅបើកូននៅតំរៀបគ្នាចឹងអី
នៅលើផ្ទះចឹងនៅមុខនៅក្រោយដុះមួយរៀប លក្ខណះបងទី1ច្រើនបន្តិច បងទី2ចុះបន្តិច បងទី3ចុះបន្តិច

ក៖ ចឹងមានន័យថាដល់ពេលដែរពៅគេអស់បាត់ហើយពូ?

ខ៖ ពៅគេគឺ

ក៖ ចឹងបានថាចុះបន្តិចៗចឹងដល់ពេលដែរពៅគេអស់បាត់ហើយពូ?

ខ៖ យើងហូបហើយធម្មតាតែយើងហូបមិនឆ្អែតយើងសម្លឹងឪហើយ
ដូចថាឪប្រាប់ដួលទឹកថែមទៅកូនផឹកទឹកទៅវាតឹងពោះហើយកូនពៅ
ខ្ញុំតាមឪខ្ញុំថែមទឹកមួយផ្ទឹលទៅ

ក៖ ពូក៏តឹងពោះមែន?

ខ៖ តឹងពោះមែននឹង

ក៖ បាទពូសប្បាយពូ ចឹងពូនិយាយកំប្លែងហើយសប្បាយ

ខ៖ នេះខ្ញុំនិយាយនឹងអត់មានលើសលុបអីទេ

ក៖ បាទដូចថាវាអញ្ចឹងមែនពូ

ខ៖ និយាយរួមប្រវត្តិការពិតរបស់ខ្ញុំគឺល្វីង ជូរចត់ចឹងមែនលោកគ្រូ

ក៖ បាទចឹងពូគិតថានៅក្នុងជីវិតរបស់ពូ
តើពូគិតថាពេលណាដែរពូគិតថាសប្បាយជាងគេដែរហាសពូ
ដែរពូគិតថាពូចាំមិនភ្លេចដូចជាការកូន
រឺការខ្លួនអែងដែរពូចាំមិនភ្លេចហាសពេលណាដែរពូ?

ខ៖ ចាំចាប់ផ្ដើមសប្បាយនឹងពេលដែរមានពួកម៉ាក់ច្រើន ពេលដែរការហើយការអីចឹងទៅពួកម៉ាក់សប្បាយចាប់ផ្ដើមសប្បាយជាមួយប្រពន្ធជាមួយពួកម៉ាក់ចឹងទៅ មានពួកម៉ាក់ដើរទៅលេងបុណ្យទានអីសប្បាយចឹងទៅដេញធាក់គ្នា

ក៖ ម៉េចចឹងពូ?

ខ៖ ចុះកាលណុងដើរកាត់ជញ្ជាំងហោសមិនដើរដេញធាក់គ្នា ចុះកាលណុងមិនទាន់មានម៉ូសមានអីចឹងដេក ហើយទៅមើលបុណ្យទានអីចឹងទៅ ដល់ពេលថាពេលដែរស្រវឹងចឹងទៅទៅដេកនៅកណ្ដាល់ផ្លូវតាមជ្រាំងចឹងទៅ

ក៖ អូបាទៗពូចឹងហោស?

ខ៖ ចុះពេលណុងស្រុកយើងវាសប្បាយហោស យើងសប្បាយនោះមិនទានមានអី យើងបានផុតពីសង្គ្រាមផុងពីអីអស់ហើយនោះ យើងសប្បាយពីព្រោះយើងលែងមានទុក លែងមានភ័យអីអស់ហើយនឹង

ក៖ ចុះពូតាំងពីក្មេងរហូតមកដល់ពេលនេះពូគិតថាពូធ្លាប់មានក្ដីសង្ឃឹម រឺមួយក៏ក្ដីស្រម៉ៃអីថាតាំងពីក្មេងចឹងថាពូធំឡើងបួចង់ធ្វើអីចឹងពូចង់ធ្វើប៉ូលីស ហើយសំរេចតាមគោលបំណងពូមែន រឺក៏ចង់ធ្វើជាគ្រូបង្រៀន រឺគ្រូពេទ្យអីចឹងហាសពូធ្លាប់មានក្ដីស្រម៉ៃទេពូ?

ខ៖ ខ្ញុំស្រម៉ៃតាលោកគ្រូ

ក៖ ស្រម៉ៃចង់ធ្វើអីគេដែរពូ?

ខ៖ កាលពីខ្ញុំនៅតូចខ្ញុំស្រម៉ៃថាពេលដែរខ្ញុំរៀនខ្ញុំចង់ធ្វើតែពេទ្យលោកគ្រូតែអត់មានទេលោកគ្រូអើយចឹងទៅ

ក៖ ប៉ុន្តែពូបានធ្វើប៉ូលីសវិញ?

ខ៖ អត់បានប៉ូលីសក៏អត់បានដែរ

ក៖ ចឹងអត់ទេណាពូ?

ខ៖ អារនឹងខ្ញុំសំគេពួកម៉ាក់ធ្វើប៉ូលីស

កៈ អូចឹងទេហោសពូ?

ខៈ បាទពេលដែរពួកម៉ាក់មកផឹកស៊ីចឹង
ពួកម៉ាក់ថាម៉េចហែងសំលឹងមើលតែអញ់ចឹងហាស
ខ្ញុំថាអើយអញ់ប្រាថ្នាថាជាតិនេះចង់ធ្វើពេទ្យផង ធ្វើប៉ូលីសផង នឹងទាហ៊ានផង
ស្រលាញ់រឿងពេទ្យនឹងតែម្តង ចឹងពួកម៉ាក់ថាចឹងហែងយកអាវអញ់មួយទៅចឹង
ទោះអញ់មិនបានធ្វើប៉ូលីសទៅបំរើជាតិក៏អញ់បានអាវមួយដែរនឹង

កៈ ក៏បានអាវមួយដែរ

ខៈ បាទខ្ញុំគិតចឹងហាស

កៈ
ចុះបើចង់អោយពូផ្តែផ្តាំទៅកូនចៅជំនាន់ក្រោយហាសតើពូចង់ផ្តែផ្តាំអីទៅពួកគាត់ដែរពូ?

ខៈ ខ្ញុំចង់ផ្តែផ្តាំថាចង់ជួយលើកដំកើងប្រទេសជាតិយើង
ជួយលើកដំកើងប្រទេសជាតិយើងអោយបានច្រើនកាន់ការងារអី រឺខំរៀនអីអោយចេះ
ខំរៀនអីកាន់ការងារអីអោយជាប់ រៀនអោយចេះ ហើយប្រលងអោយជាប់
ហើយកុំអោយបាត់បង់នៅវប្បធិមរបស់យើង

កៈ បាទចឹងហោសពូមានអីទៀត?

ខៈ ហើយបទពីដើមៗជួយលើកឡើងវិញអោយអស់ កុំអោយភ្លេចសូមផ្តែផ្តាំប៉ុណ្ណឹង

កៈ មានអីផ្សេងទៀតអត់ពូ?

ខៈ
ខ្ញុំនឹកអាសើចតែប៉ុណ្ណឹងអ្នកចំរៀងពីជំនាន់ដើមបានស្លាប់បាត់អស់បើនៅដល់ឥឡូវមិនដឹង
ជាសប្បាយយ៉ាងណាទេនឹង នឹកឃើញខឹងថាអាពតសម្លាប់ហោស
កាលពីអាពតសម្លាប់ពីជំនាន់ដើម ទោះបីបើខ្ញុំបានជួបពិធីករអីនឹង
ក៏ខ្ញុំសុំគេដែរសុំគេអោយលើកដំកើងវប្បធិមខ្មែរយើងអោយបានខ្ពស់កុំអោយហើយចាក់ចំ
រៀងតាមឌីសនឹងបទចំរៀងពីដើមនឹង សុំអោយចាក់ឌីសអោយបានស្តាប់ខ្ញុំ
បានលឺបទចំរៀងពីដើមខ្ញុំទឹកភ្នែកហើយ

ហើយខ្ញុំបានអាណិតអ្នកនិពន្ធបទចំរៀងពីដើមណាស់
អាពតសំលាប់អស់ខ្ញុំអាណិតណាស់

កៈ បាទពូចឹងមានអីផ្សេងទៀតអត់ពូដែរពូចង់ផ្ដែផ្ដាំអត់ពូ?

ខៈ គ្មានអីទេលោកគ្រូខ្ញុំចង់ផ្ដែផ្ដាំអោយវប្បធម៌ខ្មែរយើងបានលើកដំកើងខ្ពស់នឹង

កៈ អូបាទចឹងពូ

ខៈ ហើយកូនជំនាន់ក្រោយៗនឹងបានរៀនចេះហើយនឹងប្រលងអោយជាប់
បាទលោកគ្រូហើយម៉្យាងទៀតខ្ញុំសុំ ខុសត្រូវអីសូមខ័ណ្ឌាតី
អភ័យទោសផងពីព្រោះអីខ្ញុំរះសមញ្ញនឹងចេះអោយតិចភ្លេចអោយច្រើន
ខុសត្រូវអីសូមអភ័យទោសអោយខ្ញុំផង

កៈ បាទអត់អីទេពូនេះជាប្រវត្តិរបស់ពូដែរពូបានចាំបានប៉ុណ្ណឹងចឹងហាស
ហើយអ្វីដែរពូនិយាយសុទ្ធតែជាប្រវត្តិការពិតរបស់ពូចឹងហាស
ចឹងជាចុងក្រោយខ្ញុំអរគុណពូដែរបានអោយខ្ញុំបានសំភាសន៍ពីប្រវត្តិរបស់ពូចឹងហាស
ហើយដូចជាបានផ្ដល់ពេលវេលាមួយនឹងដើម្បីបានពិភាក្សាពីប្រវត្តិមួយនឹងសំរាប់ខ្ញុំចឹងហា
សពូបាទចឹងអរគុណច្រើនពូ៕៕៕